# របស់លេង ដែលម៉ាទីន ចូលចិត្ត

ដោយ ជេ រ៉ាយអិន ជេនសិន
ទស្សនាវដ្ដីសាសនាចក្រ
( ផ្អែកទៅលើដំណើររឿងពិត )

*« ផ្ដល់ឲ្យ រួចដូចព្រះយេស៊ូវប្រទានឲ្យ មានអ្វីទាំងអស់អាចផ្ដល់ឲ្យ »* ( Children's Songbook *ទំព័រ ២៣៦* ) ។

ម៉ាទីនមានអារម្មណ៍កើតទុក្ខ ពេលឪពុកម្ដាយគាត់បានប្រាប់គាត់ថា គ្រួសារគាត់នឹងប្ដូរទៅរស់នៅទីក្រុងផ្សេងនៅប្រទេសកូឡុំប៊ី ។ គាត់ពុំចង់ទៅចោលមិត្តភក្ដិ ផ្ទះ និងកន្លែងដែលគាត់បានធំឡើងទេ ។ ជំនួសឲ្យខ្យល់ភ្នំដ៏ត្រជាក់ ម៉ាទីននឹងរស់នៅក្បែរឆ្នេរសមុទ្រដែលមានកម្ដៅ ខ្យល់សើមពេញមួយឆ្នាំ ។ គាត់នឹងប្ដូរសម្លៀកបំពាក់ក្ដៅៗជាមួយនឹងភេជ្ជសៈត្រជាក់ៗ ហើយស្លៀកខោខ្លីជំនួសឲ្យពាក់អាវរងារវិញ ។ បន្ថែមពីនោះទៀតនៅមានសាលារៀនថ្មី វួដថ្មី និងថ្នាក់អង្គការបឋមសិក្សាថ្មីផងដែរ ។ អ្វីៗទាំងអស់ហាក់ដូចជាគួរឲ្យខ្លាចណាស់ ។

ថ្ងៃមួយម៉ាក់ និងប៉ាបានសួរអារម្មណ៍ម៉ាទីនអំពីការប្ដូរទីលំនៅនោះ ។

ម៉ាទីនបាននិយាយថា « កូនមិនចូលចិត្តវាទេ ។ កូនមិនចូលចិត្តផ្លាស់ប្ដូរអ្វីៗគ្រប់យ៉ាងទេ » ។



ប៉ាបាននិយាយថា « ប៉ាដឹងថា ការប្ដូរផ្ទះជារឿងលំបាក ។ មានអ្វីជាច្រើននឹងផ្លាស់ប្ដូរ ប៉ុន្ដែមិនផ្លាស់ប្ដូរ *អ្វីគ្រប់យ៉ាងនោះទេ* ។ កូននៅតែមានម៉ាក់ និងប៉ា ! »

ម៉ាទីនបាននិយាយថា « ត្រឹមត្រូវហើយ » ។

ម៉ាក់បាននិយាយថា « ហើយកូននឹងនៅតែមានរបស់របររបស់កូនដដែល » ។

ម៉ាទីនបានគិតច្រើនអំពីរឿងនោះមួយសន្ទុះ ។ គាត់នៅតែមានសម្លៀកបំពាក់របស់គាត់ ស្បែកជើង និងរបស់របរផ្សេងទៀតដែលគាត់ស្គាល់នៅផ្ទះចាស់របស់គាត់—ជាពិសេសគឺប្រដាប់ប្រដាលេងរបស់គាត់ ។ ម៉ាទីនសប្បាយចិត្តដែលគាត់អាចយករបស់លេងដែលគាត់ចូលចិត្ត ។ គាត់បានវេចខ្ចប់វាដោយកាន់តែប្រុងប្រយ័ត្ន ពេលពួកគេប្ដូរផ្ទះ ។

មួយរយៈក្រោយមក ម៉ាទីនបានចាប់ផ្ដើមស៊ាំនឹងផ្ទះថ្មី និងទីក្រុងថ្មីរបស់គាត់ ។ គាត់សប្បាយចិត្តដែលការប្ដូរផ្ទះរបស់គាត់មិនពិបាក ឬគួរឲ្យភ័យដូចគាត់បានគិតទេ ។

បន្ទាប់មកនៅថ្ងៃអាទិត្យមួយ ពេលគ្រួសារគាត់ទៅព្រះវិហារ ម៉ាទីនបានជួបមនុស្សច្រើនដែលគាត់ពុំធ្លាប់ជួបពីមុន ។ ថ្នាក់អង្គការបឋមសិក្សាមានក្មេងៗប្លែកមុខជាច្រើន ។ គាត់ឆ្ងល់ថា តើពួកគេមកពីណា ។ គាត់បានឮមនុស្សដែលគាត់ស្គាល់និយាយអំពីការបរិច្ចាគអាហារ សម្លៀកបំពាក់ និងស្បែកជើង ។ បន្ទាប់ពីព្រះវិហារ ម៉ាទីនបានសួរម៉ាក់អំពីមនុស្សប្លែកមុខទាំងអស់នោះ ។

ម៉ាក់បានពោលថា « ពួកគេត្រូវចាកចេញពីប្រទេសរបស់ពួកគេ ។ ពួកគេជាច្រើនបានចាកចោលអ្វីៗគ្រប់យ៉ាងឥឡូវនេះពួកគេគ្មានអ្វីទេ » ។



ម៉ាទីនបានសួរ « អញ្ចឹង នោះគឺជាមូលហេតុដែលមនុស្សគ្រប់គ្នាចង់ជួយពួកគេឬ ? »

« ត្រឹមត្រូវហើយ ។ ព្រះយេស៊ូវបានបង្រៀនយើងថា យើងគួរតែជួយមនុស្សដែលត្រូវការជំនួយ ។ យើងអាចធ្វើតាមគំរូរបស់ទ្រង់ ហើយចែកចាយអ្វីដែលយើងមាន » ។

ម៉ាទីនបានគិតថា នឹងមានកិច្ចការល្អដែលអាចធ្វើបាន ។

បន្ទាប់មកម៉ាក់បាននិយាយថា « ក្មេងៗជាច្រើនមកពីថ្នាក់អង្គការបឋមសិក្សាមានសម្ភារតែក្នុងកាបូបរបស់ពួកគេប៉ុណ្ណោះ ។ ពួកគេត្រូវទុកប្រដាប់ប្រដាលេងរបស់ពួកគេចោល ។ តើកូនគិតថា កូនមានប្រដាប់លេងដែលកូនអាចឲ្យទៅគេបានដែរឬទេ ? »

« ទេ ! នោះជាប្រដាប់លេងរបស់កូនទេ ! » ម៉ាទីននិយាយ ។ គាត់បានបែរមុខចេញ ហើយរត់ទៅក្នុងបន្ទប់គាត់ ។

ម៉ាទីនបានមើលជុំវិញបន្ទប់គាត់ទាំងយំ ។ គាត់មិនចង់ឲ្យប្រដាប់លេងទៅនរណាទេ ។ គាត់ខំយកវាតាំងពីផ្ទះចាស់គាត់មក !

គាត់បានទៅកាន់ប្រអប់ដាក់ប្រដាប់លេងរបស់គាត់ ហើយបានមើលក្នុងប្រអប់នោះ ។ គាត់បានឃើញឡានជ័រ, យ៉ូយ៉ូ, វ៉ូ កាបូបដ៏ល្អរបស់គាត់ធ្វើពីថ្មម៉ាប និងប្រដាប់លេងជាច្រើនទៀតដែលគាត់ចូលចិត្ត ។ គាត់ចូលចិត្តប្រដាប់លេងទាំងអស់ ។ គាត់ពុំអាចឲ្យវាទៅនរណាទេ !

បន្ទាប់មក ម៉ាទីនគិតថា « ចុះមានអ្វីកើតឡើងប្រសិនបើខ្ញុំចាកចោលផ្ទះ ហើយទុកចោលប្រដាប់លេងដែលខ្ញុំចូលចិត្តនោះ ? »

ពីរបីនាទីក្រោយមក គាត់បានទៅជួបម៉ាក់ដោយឱបប្រដាប់លេងពេញដៃគាត់—មិនគ្រាន់តែប្រដាប់លេងចាស់ៗប៉ុណ្ណោះទេ—ថែមទាំងប្រដាប់លេងដែលគាត់តែងតែលេងជាមួយផងដែរ ។

ម៉ាក់បានមើលដោយក្ដីភ្ញាក់ផ្អើល ។ « កូនមិនចាំបាច់ត្រូវឲ្យប្រដាប់លេងដែលកូនចូលចិត្តទេ » ។

ម៉ាទីនបានដាក់ប្រដាប់លេងនៅលើកម្រាលឥដ្ឋ ។ គាត់បាននិយាយថា « ក្មេងផ្សេងទៀតក៏មានប្រដាប់លេងដែលពួកគេចូលចិត្តផងដែរ ។ កូនចង់ឲ្យប្រដាប់លេងរបស់កូនទៅពួកគេ ដើម្បីពួកគេអាចសប្បាយចិត្តបន្តិច » ។

ម៉ាក់បានឱបម៉ាទីន ។ « ម៉ាក់មានមោទនភាពចំពោះកូនណាស់ » ។

ម៉ាទីនមានអារម្មណ៍កក់ក្ដៅក្នុងចិត្ត ។ គាត់បានដឹងថា ការឲ្យអ្វីមួយទៅមនុស្សដទៃគឺជាអ្វីដែលព្រះយេស៊ូវនឹងធ្វើ ហើយវាធ្វើឲ្យទ្រង់សប្បាយព្រះទ័យ ។●



### ទង្វើសាមញ្ញ

« យើងអាចបង្ហាញសេចក្ដីស្រឡាញ់ និងការដឹងគុណរបស់យើងចំពោះព្រះអង្គសង្គ្រោះ . . . តាមរយៈទង្វើនៃការបម្រើដ៏សាមញ្ញ។ និងក្ដីអាណិតអាសូររបស់យើង ដល់បងប្អូនប្រុសស្រីរបស់យើងនៅផ្ទះ នៅព្រះវិហារ និងនៅក្នុងសហគមន៍របស់យើង » ។

ប្រធាន អិម រ័សុល បាឡឺដ ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់
« Finding Joy through Loving Service » *Liahona*
ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៤៩ ។